mnvotes.gov

1-877-600-VOTE (8683)

MN Relay Service: 711

secretary.state@state.mn.us

## សូមអបអរសាទរ អ្នកនឹងត្រូវបានចុះឈ្មោះបោះឆ្នោត!

ស្របតាមពាក្យសុំប័ណ្ណបើកបរថ្មីៗ ឬអត្តសញ្ញាណប័ណ្ណរដ្ឋរបស់អ្នក អ្នកនឹងត្រូវបានចុះឈ្មោះបោះឆ្នោតនៅរដ្ឋមីណេសូតា។

### អ្នកមានជម្រើស 2

- **មិនចាំបាច់ធ្វើអ្វី** ហើយអ្នកនឹងត្រូវបានចុះឈ្មោះបោះឆ្នោត។ ការិយាល័យបោះឆ្នោតក្នុងតំបន់របស់អ្នកនឹងផ្ញើកាតប្រៃសណីយ៍ដែលមានសរសេរស្រុក/ខណ្ឌ មណ្ឌល និងទីតាំងបោះឆ្នោតរបស់អ្នក។
- **បដិសេធមិនចុះឈ្មោះ** ប្រសិនបើអ្នកមិនចង់ចុះឈ្មោះ ឬមិនមានសិទ្ធិបោះឆ្នោតទេ (មើលព័ត៌មានលម្អិតនៅខាងក្រោយ) សូមផ្ញើទម្រង់បែបបទខាងក្រោមទៅវិញក្នុងរយៈពេល 20 ថ្ងៃ រាប់ចាប់ពីថ្ងៃផ្ញើសំបុត្រនេះ នោះអ្នកនឹងមិនត្រូវបានចុះឈ្មោះបោះឆ្នោតទេ។

---

## ប្រសិនបើអ្នកមិនចង់ចុះឈ្មោះបោះឆ្នោតទេ

សូមធីកប្រអប់ខាងក្រោម ចុះហត្ថលេខា ហើយផ្ញើទម្រង់បែបបទនេះទៅវិញ ប្រសិនបើអ្នកមិនមានសិទ្ធិបោះឆ្នោត (មើលព័ត៌មានលម្អិតនៅខាងក្រោយ) ឬអ្នកមិនចង់ចុះឈ្មោះ។

| | |
|---|---|
| 1 | ☐ យោងតាមច្បាប់រដ្ឋមីណេសូតាលេខ 201.161 ផ្នែករងទី 2 ខ្ញុំបដិសេធមិនចុះឈ្មោះ ឬចុះឈ្មោះមុនពេលដើម្បីបោះឆ្នោតនៅរដ្ឋមីណេសូតាទេ។ ឬប្រសិនបើចាប់ពីថ្ងៃផ្ញើសំបុត្រមកកន្លងហួស 20 ថ្ងៃ ហើយខ្ញុំបានចុះឈ្មោះបោះឆ្នោតរួចហើយ ខ្ញុំស្នើឱ្យលុបឈ្មោះចេញពីបញ្ជីអ្នកបោះឆ្នោតស្របតាមច្បាប់រដ្ឋមីណេសូតាលេខ 201.13 ផ្នែករងទី 4។ |
| 2 | ខ្ញុំសូមសច្ចា ឬបញ្ជាក់ថា ខ្ញុំគឺជាបុគ្គលដែលទម្រង់បែបបទនេះត្រូវបានចេញជូន។<br>ហត្ថលេខា<br>X |
| 3 | ផ្ញើទម្រង់បែបបទនេះទៅវិញ<br>ប្រើស្រោមសំបុត្រដែលផ្តល់ជូន អ៊ីមែល ឬទូរសារ។ |

ត្រឡប់ដើម្បីមើលព័ត៌មានបន្ថែម →

## នៅរដ្ឋមីណេសូតា អ្នកមានសិទ្ធិចុះឈ្មោះបោះឆ្នោត ប្រសិនបើអ្នក...

- មានអាយុយ៉ាងតិច 16 ឆ្នាំក្នុងការចុះឈ្មោះជាមុន និងយ៉ាងតិច 18 ឆ្នាំនៅថ្ងៃបោះឆ្នោតដែលអ្នកមានបំណងបោះឆ្នោត
- គឺជាពលរដ្ឋសហរដ្ឋអាមេរិក
- បន្តរស់នៅក្នុងរដ្ឋមីណេសូតាយ៉ាងតិច 20 ថ្ងៃ មុនថ្ងៃបោះឆ្នោត
- មិនស្ថិតក្រោមអាណាព្យាបាលភាពដែលតុលាការបង្គាប់ឱ្យដកហូតសិទ្ធិបោះឆ្នោត
- មិនត្រូវបានរកឃើញដោយតុលាការថាអសមត្ថភាពក្នុងការបោះឆ្នោតតាមផ្លូវច្បាប់
- បច្ចុប្បន្នមិនជាប់ឃុំដោយការផ្តន្ទាទោសពីបទឧក្រិដ្ឋ

**ប្រសិនបើអ្នកមិនត្រូវតាមលក្ខខណ្ឌខាងលើទេ សូមបដិសេធមិនចុះឈ្មោះដោយប្រើទម្រង់បែបបទនៅម្ខាងទៀត។**

## អ្វីដែលអ្នកត្រូវដឹង

- អ្នកបំពេញពាក្យនៅទីភ្នាក់ងាររដ្ឋដែលមានសិទ្ធិ និងផ្តល់ឯកសារបញ្ជាក់សញ្ជាតិអាមេរិកនឹងត្រូវបានចុះឈ្មោះបោះឆ្នោតដោយស្វ័យប្រវត្តិ។
- ចុះឈ្មោះដោយគ្មានការពន្យារពេលតាមអនឡាញនៅ mnvotes.gov/register ឬនៅការិយាល័យចុះឈ្មោះប្រចាំខោនធី។
- កាលបរិច្ឆេទសម្រាប់ការចុះឈ្មោះជាមុនគឺ 21 ថ្ងៃ មុនថ្ងៃបោះឆ្នោត។ ទោះយ៉ាងណា អ្នកអាចចុះឈ្មោះនៅថ្ងៃបោះឆ្នោតនៅកន្លែងបោះឆ្នោតរបស់អ្នកបាន។ សូមចូលមើល *mnvotes.gov* ដើម្បីស្វែងយល់ថាអ្នកនឹងត្រូវការឯកសារ និងលិខិតបញ្ជាក់អត្តសញ្ញាណអ្វីខ្លះដើម្បីចុះឈ្មោះ។
- ព័ត៌មានអំពីការចុះឈ្មោះអ្នកបោះឆ្នោតជាក់លាក់មានផ្តល់ជូនជាសាធារណៈ នៅពេលប្រើសម្រាប់គោលបំណងបោះឆ្នោតនយោបាយ អនុវត្តច្បាប់ ឬជ្រើសរើសគណៈវិនិច្ឆ័យ។ ប្រសិនបើអ្នកមានក្តីបារម្ភអំពីសុវត្ថិភាពផ្ទាល់ខ្លួន អ្នកអាចរក្សាព័ត៌មានទំនាក់ទំនងរបស់អ្នកជាឯកជន។ សូមហៅទូរសព្ទទៅលេខ 1-877-600-8683 ដើម្បីស្វែងយល់បន្ថែម។

**ចូលមើល mnvotes.gov ដើម្បីស្វែងរកកន្លែងបោះឆ្នោត ដាក់ពាក្យសុំសន្លឹកឆ្នោតសម្រាប់បុគ្គលអវត្តមាន មើលសន្លឹកឆ្នោតគំរូ ធ្វើបច្ចុប្បន្នភាពការចុះឈ្មោះរបស់អ្នក និងច្រើនទៀត។**

## ធនធានអំពីការចុះឈ្មោះអ្នកបោះឆ្នោតជាភាសាផ្សេងទៀត

ព័ត៌មាននេះមានផ្តល់ជូនជាភាសាទាំងនេះនៅ mnvotes.gov/register ឬដោយស្កេនកូដ QR នេះ។

Español Soomaali Русский ພາສາລາວ ខ្មែរ

Hmoob Tiếng Việt 中文 Oromo አማርኛ

ត្រឡប់ដើម្បីមើលជម្រើស →